**សុន្ទរកថាស្វាគមន៍**

**របស់**

# ឯកឧត្តម ញ៉ូវ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

# ក្នុងពិធីបើកសន្និបាតបូកសរុបសមិទ្ធផលការងារក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី២

ក្រសួងមហាផ្ទៃ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១

-សូមគោរពអង្គសន្និបាតជាទីគោរព
-សូមគោរព **ឯកឧត្តម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
-សូមគោរព ឯកឧត្តម លោកជំទាវ លោកស្រីអស់លោក.......

ជាបឋមតាងនាមឱ្យគណៈកម្មការរៀបចំសន្និបាត និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ជាមួយនឹងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **ឯកឧត្តម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប ដែលបានផ្តួចផ្តើមគំនិត និងគាំទ្រឱ្យមានការរៀបចំសន្និបាតបូកសរុបសមិទ្ធផលការងារក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី២ និងឆ្លៀតឱកាសដ៏មមាញឹករបស់ឯកឧត្តមអញ្ជើញចូលរួមជាអធិបតី ក្នុងនាមតំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកសន្និបាតដ៏មហោឡារិកនាថ្ងៃនេះ។

ខ្ញុំសូមសម្តែងនូវគារវកិច្ច និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម លោកជំទាវ លោកស្រី អស់លោកទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងសន្និបាតនាថ្ងៃនេះ។

ខ្ញុំជឿជាក់ថាសន្និបាតនាពេលនេះ ពិតជានឹងផ្តល់ឱកាសដល់ឯកឧត្តម លោកជំទាវ លោកស្រី អស់លោកទាំងអស់បានចូលរួមពិនិត្យ និងវាយតម្លៃអំពីសមិទ្ធផលនានា ដែលក្រុមប្រឹក្សាឃុំ-សង្កាត់នៅទូទាំងប្រទេសសំរេចបាន រួមទាំងបញ្ហាលំបាកទាំងឡាយដែលក្រុមប្រឹក្សានៅថ្នាក់មូលដ្ឋានទាំងអស់នោះ បាន និងកំពុងប្រឈមក្នុងរយៈពេលជិតដប់ឆ្នាំកន្លងមក ដើម្បីចែករំលែកនូវគំនិត និងបទពិសោធន៍ល្អៗ សំរាប់ជម្រុញដំណើរការអនុវត្តនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សំដៅបន្តរួមចំណែកធ្វើជាគ្រឹះរឹងមាំដល់ការបង្កើត ការលើកកំពស់ និងការធ្វើឱ្យមានចិរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅកម្ពុជា។

ដូចយើងទាំងអស់គ្នាបានជ្រាបស្រាប់ហើយថា នយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាលលើវិស័យរដ្ឋបាលសាធារណៈតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ដែលត្រូវបានអនុវត្ត និងលេចចេញជារូបរាងជាលើកដំបូងនៅកម្ពុជាចាប់តាំងពីឆ្នាំ២០០២មកនោះ បានបង្កើតឡើងនូវអង្គភាពអភិបាលកិច្ចមូលដ្ឋានគ្រប់គ្រងដោយក្រុមប្រឹក្សាកើតចេញពីការបោះឆ្នោតផ្ទាល់របស់ប្រជាពលរដ្ឋ ដែលដឹកនាំការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងឃុំ-សង្កាត់របស់ខ្លួនទាំង១៦២១ រហូតមកដល់បច្ចុប្បន្ន។

ដំណើរការនេះ បានផ្តល់នូវមូលដ្ឋានគ្រឹះ និងមេរៀនពិសោធន៍ដ៏រឹងមាំដល់រាជរដ្ឋាភិបាលក្នុងការបង្កើតក្របខណ្ឌយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីពង្រីកវិសាលភាព នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែទូលំទូលាយនៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល ។ អាស្រ័យហេតុនេះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក៏កាន់តែមានលទ្ធភាពគាំទ្រដល់ការរក្សាស្ថេរភាព និងការអភិវឌ្ឍនៅឃុំ-សង្កាត់ រួមចំណែកដល់ការកាត់បន្ថយភាពក្រីរបស់ប្រជាពលរដ្ឋ ។

ជារួម ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការបានផ្តល់ឱ្យសង្គមយើងនូវការផ្លាស់ប្តូរសំខាន់ពីរនោះគឺ ការផ្លាស់ប្តូរនៃទំនាក់ទំនងរវាងប្រជាជនជាមួយនឹងរដ្ឋក្នុងការរួមគ្នាកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត (មូលធនសង្គម) និងការផ្លាស់ប្តូរផ្នត់គំនិតនៃទំនាក់ទំនងរវាងប្រជាជនជាមួយនឹងប្រជាជន ក្នុងការចូលរួមកសាង និងអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន (មូលធននយោបាយ) ។

ប៉ុន្តែជាក្រីត្យក្រម វឌ្ឍនភាពតែងតែប្រឈមនឹងបញ្ហាលំបាក ដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នាដោះស្រាយ ។ ការពិតដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់យើង ដែលបានរួមចំណែកបង្កើតឡើងនូវមូលធនសង្គម និងមូលធននយោបាយ ជាផ្នែកពីរដ៏មានសារៈសំខាន់មិនអាចខ្វះបានសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅតែប្រឈមនឹងកង្វះខាតផ្នែក សមត្ថភាព និងធនធាន ពិសេសធនធានហិរញ្ញវត្ថុ។ ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសកល គឺពិតជាបានបន្ថែមទំងន់ទៅលើបញ្ហាប្រឈមដែលយើងបាន និងកំពុងពុះពាររែកពុនក្នុងពេលបច្ចុប្បន្ន។ ប្រការនេះក៏បានបង្ហាញឱ្យយើងឃើញកាន់តែច្បាស់ថា ដើម្បីចូលរួមចំណែកដោះស្រាយបញ្ហាប្រឈម ដែលជាផលវិបាកនៃមុខអសកម្មរបស់សកលភាវូបនីយកម្ម គឺការពង្រឹងមូលដ្ឋានភាវូបនីយកម្មឱ្យកាន់តែមានប្រសិទ្ធិភាពជាក់ស្តែង ស្របនឹងបរិបទរបស់កម្ពុជា ។

អាស្រ័យហេតុនេះ ការបន្តជំរុញដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាការប្តេជ្ញាចិត្តដ៏មោះមុតក្នុងពេលចំពោះមុខ និងអនាគតយូរអង្វែងរបស់យើង ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះដៃគូរអភិវឌ្ឍ និងតំណាងសង្គមស៊ីវិល ដែលបានរួមចំណែកគាំទ្រដល់ដំណើរការកំណែទម្រង់របស់យើងតាំងពីដើមរហូតមកដល់បច្ចុប្បន្ន ។

ខ្ញុំក៏សូមសំដែងសាជាថ្មីម្តងទៀត នូវការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះ វិភាគទានមិនអាចកាត់ថ្លៃបានរបស់គ្រប់ផ្នែកគ្រប់ថ្នាក់ និងមន្ត្រីរាជការ ព្រមទាំងប្រជាពលរដ្ឋទូទាំងប្រទេសចំពោះបុព្វហេតុនៃកំណែទម្រង់ដ៏ថ្លៃថ្លារបស់យើងនេះ ។

មុននឹងបញ្ចប់ ខ្ញុំសូមជូនពរសន្និបាតបូកសរុបសមិទ្ធផលការងារក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី២ ទទួលបានជោគជ័យតាមការគ្រោងទុក ។

*សូមអរគុណ!*